**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

..........

28/8

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណី
លេខ: ៥៧១
ចុះថ្ងៃទី ៣០-០៣-២០១២
សាលក្រមរដ្ឋប្បវេណី
លេខ ៥០ (ខ)
ចុះថ្ងៃទី ២២-១០-២០១២

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

-បានធ្វើនីតិវិធីទាញហេតុផលផ្ទាល់មាត់ នៅបន្ទប់សវនាការទី៣ នៅថ្ងៃទី ២៥-០៩-២០១២ នៃសាលាដំបូងរាជធានីភ្នំពេញ វេលាម៉ោង៨ព្រឹក ។

-កាលបរិច្ឆេទបញ្ចប់នីតិវិធីទាញហេតុផលផ្ទាល់មាត់នៅថ្ងៃទី២៥-០៩-២០១២ ។

-កាលបរិច្ឆេទប្រកាសសាលក្រមនៅថ្ងៃទី ២២-១០-២០១២ វេលាម៉ោង៨ និង០០នាទី ព្រឹក ។

**ដោយមានសមាសភាព:**

**ចៅក្រមជំនុំជំរះ**

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

រវាងដើមចោទដែលមានឈ្មោះ [redacted] ចាន់យ៉ារ៉េត ភេទប្រុស អាយុ ៥០ឆ្នាំ ជាតិខ្មែរ មុខរបរ អនុប្រធាននាយកដ្ឋាន អាស័យដ្ឋាននៅផ្ទះលេខ៥០ABE$_0$ ផ្លូវលេខ ២៤៥ ក្រុម២ ភូមិ១ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ហៃ "ស" ម្ដាយឈ្មោះ [redacted] មុយ "រ" ប្រពន្ធឈ្មោះ [redacted] ស្រីមុំ "រ" ដោយមាន លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ ។

និងចុងចម្លើយឈ្មោះ [redacted] ពៅ ភេទប្រុស អាយុ ៨៧ឆ្នាំ ជាតិខ្មែរ មុខរបរ តែកុងឡាន មានអាស័យដ្ឋានផ្ទះលេខ ៦២E$_2$ ផ្លូវលេខ ២៤៥ ក្រុម២ ភូមិ១ សង្កាត់ បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ងួន "ស" ម្ដាយឈ្មោះ [redacted] អេង "ស" ប្រពន្ធឈ្មោះ [redacted] មុំ "រ" ដោយមានលោកស្រី [redacted] ជាមេធាវី តំណាងដោយអាណត្តិ ។

+ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញៈ ឲ្យឈ្មោះ [redacted] ពៅ និងប្រពន្ធឈ្មោះ [redacted] មុំ គោរពតាមលិខិតលក់ផ្ដាច់ចុះថ្ងៃទី ០៣-០២-២០១២ ដោយឲ្យឈ្មោះទាំងពីរនាក់ប្ដីប្រពន្ធប្រគល់ផ្ទះលេខ ៦២E$_2$ ផ្លូវ លេខ ២៤៥ ក្រុម២ ភូមិ១ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ មកឲ្យ ខ្លួនតាមលិខិតផ្ទេរសិទ្ធិកាន់កាប់ចុះថ្ងៃទី ០៨-០២-២០១២ (ចុះហត្ថលេខាដោយ លោកអភិបាលខណ្ឌ [redacted] យុយ នៅថ្ងៃទី១៣-០២-២០១២) និងកិច្ចសន្យាធានាអះ អាង ចុះថ្ងៃទី ០៨-០២-២០១២ ។

+ខ្លឹមសារនៃសាលក្រមដែលមេធាវីតំណាងដោយអាណត្តិឲ្យចុងចំលើយ ធ្វើបណ្ដឹងតបទាមទារឲ្យតុលាការចេញដូចខាងក្រោមៈ

១-រំលាយកិច្ចសន្យាលក់ផ្ដាច់ចុះថ្ងៃទី ០៣-០២-២០១២ ។

៣៤៧



Scanned with CamScanner

២-លុបចោលលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ១៧០/១២ ល.បអភិ ចុះថ្ងៃទី ១៣-០២-២០១២ របស់អភិបាលខណ្ឌចំការមន ។

៣-ទាមទារសំណងថ្លៃខូចខាតប្រាក់កក់ធ្វើលិខិតផ្ទេរសិទ្ធិសេវាកម្មច្បាប់ និងចំណាយផ្សេងៗទៀតចំនួន៨០.០០០.០០០រៀល ។

**អង្គហេតុ និងចំណុចវិវាទ**

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទឈ្មោះ [redacted] ចាន់យ៉ារ៉េត ធ្វើសេចក្តីថ្លែងការណ៍ថា: ក្នុងនាមខ្លួនជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទឈ្មោះ [redacted] ចាន់យ៉ារ៉េត សុំឲ្យតុលាការចេញសាលក្រមសម្រេចឲ្យឈ្មោះ [redacted] ៣៧ និងប្រពន្ធឈ្មោះ [redacted] មុំ គោរពតាមលិខិតលក់ផ្តាច់ ចុះថ្ងៃទី០៣-០២-២០១២ ដោយឲ្យឈ្មោះទាំងពីរនាក់ប្តីប្រពន្ធប្រគល់ផ្ទះលេខ ៦២$E_2$ ផ្លូវលេខ ២៤៥ ក្រុម២ ភូមិ១ សង្កាត់បឹងត្របែក ខណ្ឌចំការមន មកឲ្យខ្លួនតាមលិខិតផ្ទេរសិទ្ធិកាន់កាប់ចុះថ្ងៃទី ០៨-០២-២០១២ (ចុះហត្ថលេខាដោយលោក អភិបាលខណ្ឌ ឡូ យុយ នៅថ្ងៃទី១៣-០២-២០១២) និងកិច្ចសន្យាធានាអះអាង ចុះថ្ងៃទី០៨-០២-២០១២។

អង្គហេតុនៃការប្តឹងសុំទាមទារមានដូចតទៅ: ខ្លួនសុំរក្សាចំលើយរបស់កូនក្តីខ្លួនដដែល ដោយសុំបន្ថែមនូវចំណុចមួយចំនួនដូចខាងក្រោម: មូលហេតុថា: ផ្ទះលេខ ៦២$E_2$ផ្លូវ២៤៥ ភូមិ១ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ឈ្មោះ [redacted] ៣៧ និងប្រពន្ធឈ្មោះ [redacted] មុំ នៅពេលបានផ្ទេរសិទ្ធិកាន់កាប់ផ្ទះខាងលើមកឲ្យកូនក្តីខ្លួន រួចហើយត្រឹមខណ្ឌចំការមន ហើយកូនក្តីខ្លួនបានហៅឈ្មោះ [redacted] ៣៧ និងប្រពន្ធឈ្មោះ [redacted] មុំ មកទទួលយកប្រាក់បង្គ្រប់ដើម្បីប្រគល់ផ្ទះដែលបានផ្ទេរសិទ្ធិមកឲ្យកូនក្តីខ្លួនជាច្រើនលើកច្រើនសារតែឈ្មោះ [redacted] ៣៧ និងប្រពន្ធឈ្មោះ [redacted] មុំ ចេះតែរកលេសមិនព្រមអនុវត្តតាមកិច្ចសន្យាលក់ទិញផ្ទះដោយពុំព្រមប្រគល់ផ្ទះដែលកូនក្តីខ្លួនបានទិញរហូតដល់បច្ចុប្បន្ន ។

ភស្តុតាងនៃការទាមទារមាន:

១-របាយការណ៍ទូរស័ព្ទហៅចេញគឺចង់បង្ហាញថា: កូនក្តីខ្លួនបានទូរស័ព្ទទៅចុងចម្លើយឲ្យមកទទួលយកប្រាក់ថ្លៃទិញផ្ទះ តែចុងចម្លើយមិនព្រមមកយកនៅថ្ងៃទី ២២-០២-២០១២ ។

២-សាក្សីឈ្មោះ [redacted] អូន និងឈ្មោះ [redacted] ផុងហ៊ី បានដឹងពីរឿងដែលកូនក្តីខ្លួនបានហៅចុងចម្លើយមកទទួលប្រាក់ជាច្រើនលើក ។

ចម្លើយតបរបស់ចុងចម្លើយ: លោកស្រី [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យចុងចំលើយឈ្មោះ [redacted] ៣៧ និងប្រពន្ធឈ្មោះ [redacted] មុំ ធ្វើបណ្តឹងតបចុះថ្ងៃទី ០៥-០៦-២០១២ មានខ្លឹមសារនៃសាលក្រមដែលដើមបណ្តឹងតបទាមទារឲ្យតុលាការចេញដូចខាងក្រោម:

១-រំលាយកិច្ចសន្យាលក់ផ្តាច់ចុះថ្ងៃទី ០៣-០២-២០១២ ។

៣៨៥



Scanned with CamScanner

២-លុបចោលលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ១៧០/១២ ល.បអភិ ចុះថ្ងៃទី ១៣-០២-២០១២ របស់អភិបាលខណ្ឌចំការមន ។

៣-សុំទាមទារសំណងថ្លៃខាតបង់ប្រាក់កក់ ធ្វើលិខិតផ្ទេរសិទ្ធិ សេវាកម្មច្បាប់ និងចំណាយផ្សេងៗទៀត ចំនួន៨០លានរៀល ។

-សេចក្តីថ្លែងការណ៍តបរបស់លោកស្រី [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យចុងចំលើយបានថ្លែងការណ៍តបថា: កាលពីថ្ងៃទី ០៣-០២-២០១២ កូនក្តីខ្លួនឈ្មោះ [redacted] ពៅ និងឈ្មោះ [redacted] មុំ បានលក់ផ្ទះឲ្យឈ្មោះ [redacted] ចាន់យ៉ារ៉េត និងប្រពន្ធឈ្មោះ [redacted] ស្រីមុំ ក្នុងតំលៃ៤៥០០០$(បួនម៉ឺនប្រាំពាន់ដុល្លារអាមេរិក) ហើយកូនក្តីខ្លួនបានទទួលប្រាក់កក់ចំនួន២០០០$(ពីរពាន់ដុល្លារអាមេរិក) នៅពេលទទួលប្រាក់កក់ហើយឈ្មោះ [redacted] ចាន់យ៉ារ៉េត បានប្រាប់កូនក្តីខ្លួនថា: គាត់នឹងប្រគល់ប្រាក់ចំនួន៤៣០០០$(បួនម៉ឺនបីពាន់ដុល្លារអាមេរិក)ទៀត នៅពេលធ្វើលិខិតផ្ទេរសិទ្ធិរួចរាល់ លុះពេលកូនក្តីខ្លួនបានធ្វើលិខិតផ្ទេរសិទ្ធិរួចរាល់នៅថ្ងៃទី ១៣-០២-២០១២ កូនក្តីខ្លួនបានប្រាប់ទៅឈ្មោះ [redacted] ចាន់យ៉ារ៉េត និងប្រពន្ធឲ្យបង់លុយថ្លៃផ្ទះបង្គ្រប់តែឈ្មោះ [redacted] ចាន់យ៉ារ៉េត និងប្រពន្ធមិនព្រមបង់ប្រាក់បង្គ្រប់ថ្លៃផ្ទះមកឲ្យកូនក្តីខ្លួន ដោយទាមទារឲ្យកូនក្តីខ្លួនឲ្យធ្វើកិច្ចសន្យាជាមួយអ្នកផ្ទះខាងក្រោមដើម្បីឲ្យប្រគល់ដីនៅសល់ខាងក្រោយផ្ទះ ដើម្បីឲ្យគាត់បានធ្វើផ្ទះលើចំណែកដីដែលនៅសល់នោះ ដោយមានម្ចាស់ផ្ទះខាងក្រោមជាសាក្សី និងធ្វើឲ្យកូនក្តីខ្លួនជាប់ប្រាក់កក់យកលុយទៅទិញផ្ទះផ្សេង ធ្វើឲ្យកូនក្តីខ្លួនកែប្រែមិនព្រមលក់ផ្ទះឲ្យឈ្មោះ [redacted] ចាន់យ៉ារ៉េត និងប្រពន្ធវិញ ។

-ភស្តុតាងក្នុងបណ្តឹងតបមាន:

១-កិច្ចសន្យាព្រមព្រៀងគឺចង់បញ្ជាក់ថា: ភាគីអ្នកទិញផ្ទះបានប្រគល់ឲ្យមេភូមិឈ្មោះ [redacted] អូន ដើម្បីសំរុះសំរួលជាមួយម្ចាស់ផ្ទះក្រោម ដូចមានក្នុងលិខិតបំភ្លឺចុះថ្ងៃទី ០៩-០៧-២០១២ ។

២-លិខិតបំភ្លឺរបស់មេភូមិ១ សង្កាត់បឹងត្របែក ចុះថ្ងៃទី ០៩-០៧-២០១២ គឺចង់បង្ហាញពីអ្នកទិញផ្ទះមិនបំពេញកាតព្វកិច្ចប្រគល់ប្រាក់ថ្លៃទិញផ្ទះនៅពេលកូនក្តីខ្លួនបានផ្ទេរសិទ្ធិកាន់កាប់ឲ្យរួចរាល់ស្របច្បាប់ហើយនៅថ្ងៃទី ១៣-០២-២០១២ ។

-តាមសេចក្តីថ្លែងការណ៍តបរបស់លោក [redacted] ឆាយ ដែលជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ [redacted] ចាន់យ៉ារ៉េត បានថ្លែងតបទៅនឹងបណ្តឹងតបចុះថ្ងៃទី ០៥-០៦-២០១២ របស់មេធាវីតំណាងដោយអាណត្តិឲ្យចុងចំលើយឈ្មោះ [redacted] ពៅ និងប្រពន្ធឈ្មោះ [redacted] មុំ មានដូចខាងក្រោម: ខ្លួនសុំច្រានចោលនូវបណ្តឹងតបចុះថ្ងៃទី ០៥-០៦-២០១២ ចោល ដោយមូលហេតុថា: ការលើកឡើងរបស់ភាគីចុងចំលើយគ្រាន់តែជាលេសមួយដើម្បីមិនលក់ផ្ទះឲ្យកូនក្តីខ្លួនតាមកិច្ចសន្យាតែប៉ុណ្ណោះ ដោយហេតុចុងចំលើយប្តឹងតបក្នុងរឿងនេះធ្វើឲ្យប៉ះពាល់ដល់កិត្តិយស និងផលប្រយោជន៍

៣៧៩



Scanned with CamScanner

កូនក្តីខ្លួន ដូច្នេះសុំទាមទារជម្ងឺចិត្ត៥០លានរៀល ។

សាក្សីឈ្មោះ [redacted] ផុងហ៊ី នាពេលទាញហេតុផលផ្ទាល់មាត់បានឆ្លើយបញ្ជាក់ថា: ខ្លួនត្រូវជាបងថ្លៃរបស់ដើមចោទ ខ្លួនជាអ្នកធ្វើកិច្ចសន្យាលក់ផ្តាច់ឈ្មោះ [redacted] ម៉ុំ បានមកនិយាយជាមួយខ្លួនថា អ្នកក្រោមបានសន្យាជាមួយគាត់ [redacted] ម៉ុំ) ថាអាចសង់នៅខាងលើបាន ។ខ្លួនក៏ព្រៀងលិខិតមួយរវាងភាគី (ក) និងភាគី (ខ) ហើយពឹងមេភូមិជួយសំរបសំរួលជាមួយអ្នកក្រោម ។នៅថ្ងៃទី១៣.០២.២០១២ ខ្លួនសួរទៅឈ្មោះ [redacted] ម៉ុំ ថា: ហេតុម៉េច មិនមកយកលុយថ្លៃផ្ទះបង្គ្រប់ ?ឈ្មោះ [redacted] ម៉ុំ ឆ្លើយថា: គាត់ឈប់លក់ហើយ ។បន្ទាប់មកខ្លួនទូរស័ព្ទសួរប្រធានភូមិ ប្រធានភូមិប្រាប់ថា: លិខិតផ្ទេរសិទ្ធិបានចុះហត្ថលេខារួចហើយ ។ពេលនោះខ្លួនឲ្យប្រធានភូមិហូតូឲ្យខ្លួនមួយសន្លឹក បន្ទាប់មកខ្លួនទូរស័ព្ទទៅសួរឈ្មោះ [redacted] ម៉ុំ តែកូនថាម្តាយឈឺគ្មានលិខិតផ្ទេរសិទ្ធិទេ ។ឈ្មោះ [redacted] ពៅ ធ្លាប់ប្រាប់ខ្លួនថាទិញផ្ទះបានហើយគឺកក់ឲ្យគេចំនួន 1500$ បន្ទាប់មកឈ្មោះ [redacted] ចាន់យ៉ារ៉េត បានប្តឹងអន្តរាគមន៍ទៅខណ្ឌជួយដោះស្រាយ តែដោះស្រាយមិនកើតដោយសារមាននារីម្នាក់ឆាឆៅ នៅពេលនោះឈ្មោះ [redacted] ចាន់យ៉ារ៉េត បានប្រាប់ឈ្មោះ [redacted] ពៅ ថា បើខ្វះខាតអាចថែម 4.000$ ទៅ 5.000$ តែឈ្មោះ [redacted] ពៅ ឆ្លើយថាមិនព្រមលក់ ។

សាក្សីឈ្មោះ [redacted] អូន បានឆ្លើយបញ្ជាក់ថា: ខ្លួនជាមេភូមិ១សង្កាត់បឹងត្របែក នៅពេលគូភាគីព្រមព្រៀងលក់ផ្ទះ គេឲ្យខ្លួនរត់ការលិខិតផ្ទេរសិទ្ធិពេលរត់ការរួចហើយ គេពឹងខ្លួនឲ្យចរចាជាមួយផ្ទះក្រោម តែគេ(ម្ចាស់ផ្ទះក្រោម) មិនព្រម ខ្លួនក៏ទៅវិញ ។រឿងប្រគល់លុយកាក់ខ្លួនមិនដឹងទេ ។ខ្លួនដឹងថាបានយកពង្រាងលិខិតព្រមព្រៀងជាមួយឈ្មោះ [redacted] ម៉ុំ ទៅនិយាយចរចាជាមួយផ្ទះខាងក្រោម តែគេមិនព្រម ខ្លួនក៏ទៅផ្ទះវិញ ។កាត់ឈ្មោះ ហើយធ្លាក់លិខិតផ្ទេរសិទ្ធិមកហើយនៅថ្ងៃទី១៣.០២.២០១២ តែខ្លួនមិនចាំថ្ងៃចរចាជាមួយម្ចាស់ផ្ទះខាងក្រោមទេ ។ កាត់ឈ្មោះហើយរយៈពេល ៧ថ្ងៃ ផ្តិតមេដៃនៅថ្ងៃទី០៦ ឬថ្ងៃទី០៧ ពង្រាងធ្វើក្រោយគេផ្តិតមេដៃលិខិតផ្ទេរសិទ្ធិ ហើយគេពឹងឲ្យយកពង្រាងទៅចរចាជាមួយផ្ទះក្រោម ។បន្ទាប់ពីបានលិខិតផ្ទេរសិទ្ធិនៅថ្ងៃទី១៣.០២.២០១២ ខ្លួនប្រគល់ឲ្យឈ្មោះ [redacted] ម៉ុំ នៅថ្ងៃទី១៣.០២.២០១២ ក្រៅពីនេះខ្លួនអត់ដឹងទេ ។ក្រោយមកឈ្មោះ [redacted] ផុងហ៊ី បានសួរខ្លួនថា: តើលិខិតផ្ទេរសិទ្ធិធ្វើរួច ឬនៅ ?ខ្លួនបានប្រាប់គាត់វិញថា: រួចហើយ ខ្លួនហូតូឲ្យគាត់មួយសន្លឹក ក្រោយពីខ្លួនប្រគល់លិខិតផ្ទេរសិទ្ធិរួច ឈ្មោះ [redacted] ផុងហ៊ី បានពឹងខ្លួនឲ្យទៅជួយមើលផ្ទះឈ្មោះ [redacted] ម៉ុំ ។ឈ្មោះ [redacted] ម៉ុំ មិននៅផ្ទះគាត់([redacted] ម៉ុំ) ទៅហាត់កីឡា ។ក្នុងលិខិតបំភ្លឺដាក់នៅថ្ងៃទី១៤.០២.២០១២ ខ្លួនសុំកែថាថ្ងៃមិនចាំវិញ ។

ចំណុចវិវាទ: គឺគ្រប់ចំណុចដែលដើមចោទប្តឹងទាមទារ និងគ្រប់ចំណុច

៣៩០



Scanned with CamScanner

ដែលដើមបណ្តឹងតបប្តឹងទាមទារ ។

-ក្នុងសំណុំរឿងក្តីខាងលើនេះគឺជារឿងការទទួលខុសត្រូវក្នុងកិច្ចសន្យា ការសុំរំលាយកិច្ចសន្យាភាគីរងគ្រោះត្រូវរកកំហុសរបស់ភាគីដែលមិនបានប្រតិបត្តិកាតព្វកិច្ចក្នុងកិច្ចសន្យា ។

-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទឆ្លើយ និង ប្តឹងសុំ ។

-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍តបរបស់មេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយឆ្លើយ និង ប្តឹងសុំ ។

-ក្រោយពីបានស្តាប់ចំលើយសាក្សីបំភ្លឺនាពេលទាញហេតុផលផ្ទាល់មាត់

-ក្រោយពីបានពិនិត្យពិចារណាសំណុំរឿងចប់សព្វគ្រប់ហើយ

**សំអាងហេតុថា**

-ពាក្យបណ្តឹងចុះថ្ងៃទី ១៦-០៨-២០១២ របស់ឈ្មោះ [redacted] ចាន់យ៉ារ៉េត ប្តឹងសុំឲ្យឈ្មោះ [redacted] ពៅ និងប្រពន្ធឈ្មោះ [redacted] មុំ គោរពតាមលិខិតលក់ផ្តាច់ចុះថ្ងៃទី ០៣-០២-២០១២ ដោយឲ្យឈ្មោះទាំងពីរនាក់ប្តីប្រពន្ធប្រគល់ផ្ទះលេខ ៦២$E_2$ ផ្លូវលេខ ២៤៥ ក្រុម២ ភូមិ១ សង្កាត់បឹងត្របែក ខណ្ឌចំការមន មកឲ្យខ្លួនតាមលិខិតផ្ទេរសិទ្ធិកាន់កាប់ចុះថ្ងៃទី ០៨-០២-២០១២ (ចុះហត្ថលេខាដោយលោក អភិបាលខណ្ឌ ឡុយុយ នៅថ្ងៃទី១៣-០២-២០១២) និងកិច្ចសន្យាធានាអះអាង ចុះថ្ងៃទី០៨-០២-២០១២ ធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមទំរង់ច្បាប់ និងគតិច្បាប់មានដូចខាងក្រោម៖

នៅថ្ងៃទី ០៣-០២-២០១២ ភាគីចុងចម្លើយឈ្មោះ [redacted] ពៅ និងប្រពន្ធឈ្មោះ [redacted] មុំ បានព្រមព្រៀងលក់ផ្ទះលេខ ៦២$E_2$ ផ្លូវលេខ ២៤៥ ក្រុម២ ភូមិ១ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ឲ្យទៅដើមចោទឈ្មោះ [redacted] ចាន់យ៉ារ៉េត និងប្រពន្ធឈ្មោះ [redacted] ស្រីមុំ ក្នុងតំលៃ៤៥.០០០$(បួនម៉ឺនប្រាំពាន់ដុល្លារអាមេរិក) ដោយភាគីដើមចោទបានកក់ប្រាក់ចំនួន២.០០០$(ពីរពាន់ដុល្លារអាមេរិក) តាមលិខិតលក់ផ្តាច់ចុះថ្ងៃទី ០៣-០២-២០១២ រវាងឈ្មោះ [redacted] ពៅ និងប្រពន្ធឈ្មោះ [redacted] មុំ ជាអ្នកលក់ ហើយឈ្មោះ [redacted] ចាន់យ៉ារ៉េត និងប្រពន្ធឈ្មោះ [redacted] ស្រីមុំ ជាអ្នកទិញ។ នៅថ្ងៃទី ០៨-០២-២០១២ ដើមចោទ និងចុងចម្លើយក៏បានផ្តិតមេដៃលើលិខិតផ្ទេរសិទ្ធិកាន់កាប់ផ្ទះលេខ ៦២$E_2$ ខាងលើ ហើយឲ្យលោកមេភូមិ១ ឈ្មោះ [redacted] អូន ជាអ្នករត់ការកាត់ឈ្មោះផ្ទះលេខ ៦២$E_2$ ខាងលើ លុះដល់ថ្ងៃទី ១៣-០២-២០១២ លិខិតផ្ទេរសិទ្ធិកាន់កាប់ផ្ទះលេខ ៦២$E_2$ ខាងលើបានកាត់ឈ្មោះដោយចុះហត្ថលេខាពីប្រធានក្រុម, មេភូមិ , ចៅសង្កាត់ និងលោកអភិបាលខណ្ឌចំការមនរួចរាល់ ប៉ុន្តែភាគីចុងចំលើយបែរជាក្រឡះឈប់លក់ផ្ទះលេខ ៦២$E_2$ វិញ ទោះបីដើមចោទឈ្មោះ [redacted] ចាន់យ៉ារ៉េត ជាអ្នកទិញបានព្យាយាមទូរស័ព្ទនៅថ្ងៃទី ១៣-០២-២០១២ ចំនួន២លើក និងនៅថ្ងៃទី ២២-០២-២០១២ ចំនួន២លើក ហើយសាក្សី ឈ្មោះ [redacted] ជុងហ៊ ក៏បានបញ្ជាក់នាពេលទាញហេតុផលផ្ទាល់មាត់ថា នៅថ្ងៃទី ១៣-០២-២០១២ ខ្លួនសួរទៅឈ្មោះ [redacted] មុំ ថា ម៉េចមិនមកយកលុយថ្លៃផ្ទះបង្គ្រប់ ? ហើយ ឈ្មោះ [redacted] មុំ ឆ្លើយថា

៣៩១

ឈប់លក់ហើយ ។ នៅថ្ងៃទី ២៣-០២-២០១២ ដើមចោទ ឈ្មោះ [redacted] ចាន់យ៉ារ៉េត ធ្វើលិខិតសុំអន្តរាគមន៍ទៅលោកអភិបាលខណ្ឌចំការមនសំណើសុំឲ្យចុងចម្លើយឈ្មោះ [redacted] ពៅ និងប្រពន្ធឈ្មោះ [redacted] មុំ អនុវត្តកាតព្វកិច្ច ប្រគល់ផ្ទះលេខ ៦២$E_2$ ខាងលើ និងសុំឲ្យភាគីចុងចម្លើយទទួលយកប្រាក់ថ្លៃផ្ទះលេខ៦២$E_2$បង្គ្រប់ ប៉ុន្តែភាគីចុងចម្លើយ បដិសេធរហូត ពុំព្រមអនុវត្តតាកាតព្វកិច្ចទទួលប្រាក់ថ្លៃឈ្នួលផ្ទះលេខ ៦២$E_2$ បង្គ្រប់ ចំនួន៤៣.០០០$(បួនម៉ឺនបីពាន់ដុល្លារអាមេរិក) និងប្រគល់ផ្ទះលេខ ៦២$E_2$ ទៅឲ្យដើម ចោទឈ្មោះ [redacted] ចាន់យ៉ារ៉េត និងប្រពន្ធឈ្មោះ [redacted] ស្រីមុំ ឡើយ ។

-យោងតាមមាត្រា ៤០៧ នៃក្រមរដ្ឋប្បវេណីបានចែងថា ភាគីម្ខាងនៃកិច្ចសន្យាអញ្ញមញ្ញអាចរំលាយកិច្ចសន្យាបានភ្លាម។ ក្នុងករណីដែលភាគីម្ខាងទៀតបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ។ ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរមានចែងនៅក្នុងមាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណី ។ ដូច្នេះតុលាការពុំឃើញមានភស្តុតាងណាមួយបញ្ជាក់ថា ភាគីដើមចោទឈ្មោះ [redacted] ចាន់យ៉ារ៉េត និងប្រពន្ធឈ្មោះ [redacted] ស្រីមុំ បានបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរនោះឡើយ ។

ភាគីដើមចោទបានអនុវត្តកាតព្វកិច្ចនៅក្នុងកិច្ចសន្យាលក់ផ្តាច់ចុះថ្ងៃទី០៣-០២-២០១២ យ៉ាងខ្ជាប់ខ្ជួន ដូចជាតាំងពីធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ផ្ទះលេខ ៦២$E_2$ រួចនៅថ្ងៃទី១៣-០២-២០១២ ភាគីដើមចោទបានទូរស័ព្ទទាក់ទងរហូតនៅថ្ងៃទី ១៣-០២-២០១២ ចំនួន២ដងនឹងថ្ងៃទី២២-០២-២០១២ ចំនួន២ដងមានរបាយការណ៍ទូរស័ព្ទរបស់ក្រុមហ៊ុន MOBITEL ,សាក្សីឈ្មោះ [redacted] ជុងហ៊ា និងលិខិតសុំអន្តរាគមន៍ចុះថ្ងៃទី ២៣-០២-២០១២ ជាភស្តុតាង ។ ដូច្នេះតុលាការគប្បីសំរេចទទួលស្គាល់ចំណុចទាមទារនៅក្នុងពាក្យបណ្តឹងចុះថ្ងៃទី ១៦-០៨-២០១២ របស់ដើមចោទឈ្មោះ [redacted] ចាន់យ៉ារ៉េត ទាំងមូលលើកលែងតែ មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទសុំទាមទារជម្ងឺចិត្តចំនួន៥០លានរៀលនៅនីតិវិធីត្រៀមសម្រាប់ទាញហេតុផលត្រូវច្រានចោល ។

-ពាក្យបណ្តឹងតបចុះថ្ងៃទី ០៥-០៦-២០១២ របស់មេធាវី [redacted] ប្តឹងសុំៈ

១-រំលាយកិច្ចសន្យាលក់ផ្តាច់ចុះថ្ងៃទី ០៣-០២-២០១២ ។

២-លុបចោលលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ១៧០/១២ ល.បអភិ ចុះថ្ងៃទី ១៣-០២-២០១២ របស់អភិបាលខណ្ឌចំការមន ។

៣-សុំទាមទារសំណងថ្លៃខាតបង់ប្រាក់កក់ ធ្វើលិខិតផ្ទេរសិទ្ធិ សេវាកម្មច្បាប់ និងចំណាយផ្សេងៗទៀត ចំនួន៨០លានរៀល ។

ការទាមទារក្នុងចំណុចនៃបណ្តឹងតបចុះថ្ងៃទី០៥-០៦-២០១២ របស់មេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយធ្វើឡើងមានលក្ខណៈ ត្រឹមត្រូវតាមទំរង់ច្បាប់ តែផ្ទុយនឹងគតិច្បាប់ ។

ផ្ទុយនឹងគតិច្បាប់ដោយហេតុថាៈ

+ក្រោយពីធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ផ្ទះលេខ ៦២$E_2$ រួចនៅថ្ងៃទី ១៣-០២-២០១២ មកភាគីចុងចម្លើយពុំបានទុកពេលសមរម្យឲ្យភាគីដើមចោទអនុវត្តកាតព្វកិច្ចបង់ប្រាក់ថ្លៃផ្ទះលេខ៦២$E_2$ បង្គ្រប់ចំនួន៨៣.០០០$(បួនម៉ឺនបីពាន់ដុល្លារអាមេរិក)



Scanned with CamScanner

ឡើយ ឮយ៉ាងដូចជាលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ១៧០/១២ ល.ប អភិ ចុះថ្ងៃទី ១៣-០២-២០១២ រហូតដល់ភាគីដើមចោទឈ្មោះ [redacted] ចាន់យ៉ារ៉េត ដាក់ពាក្យ សុំអន្តរាគមន៍ទៅលោកអភិបាលខណ្ឌចំការមនដើម្បីសុំអនុវត្តកាតព្វកិច្ចបង់ប្រាក់ថ្លៃផ្ទះលេខ ៦២$E_2$ បង្គ្រប់ចំនួន៤៣.០០០$(បួនម៉ឺនបីពាន់ដុល្លារ អាមេរិក) និងសុំឲ្យភាគីចុងចម្លើយប្រគល់ផ្ទះលេខ៦២$E_2$មកឲ្យភាគីដើមចោទមានរយៈពេលត្រឹម១០ថ្ងៃតែប៉ុណ្ណោះ ។ ដូច្នេះភាគីដើមចោទមិនបានខកខានក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួននៅក្នុងកិច្ចសន្យា ឡើយ ។

+ពុំមានភស្តុតាងអ្វីបញ្ជាក់ឲ្យតុលាការឃើញថា: ភាគីចុងចម្លើយឈ្មោះ [redacted] ពៅ និងប្រពន្ធឈ្មោះ [redacted] មុំ ជាអ្នកលក់បានដាស់តឿនឲ្យភាគីដើមចោទឈ្មោះ [redacted] ចាន់យ៉ារ៉េត និងប្រពន្ធឈ្មោះ [redacted] ស្រីមុំ ជាអ្នកទិញ ដើម្បីអនុវត្តកាតព្វកិច្ចបង់ប្រាក់បង្គ្រប់ថ្លៃផ្ទះលេខ ៦២$E_2$ ខាងលើឡើយ ។

+ការសុំរំលាយកិច្ចសន្យារបស់ភាគីណាមួយបានលុះត្រាតែភាគីម្ខាងទៀតមិនព្រមអនុវត្តកាតព្វកិច្ចនៅក្នុងកិច្ចសន្យាពោលគឺភាគីម្ខាងទៀតបានបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ។ ភាគីដើមចោទពុំបានបំពានកិច្ចសន្យាឡើយ ។

ដូច្នេះមេធាវីតំណាងដោយអាណត្តិឲ្យភាគីចុងចម្លើយឈ្មោះ [redacted] ពៅ និងប្រពន្ធឈ្មោះ [redacted] មុំ ធ្វើបណ្តឹងតបពុំមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ភាគីដើមចោទឈ្មោះ [redacted] ចាន់យ៉ារ៉េត និងប្រពន្ធឈ្មោះ [redacted] ស្រីមុំ មានកំហុសក្នុងការអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យាដើម្បីឲ្យតុលាការអាចរំលាយកិច្ចសន្យាលក់ផ្តាច់ចុះថ្ងៃទី ០៣-០២-២០១២ និងលុបចោលលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ១៧០/១២ ល.បអភិ ចុះថ្ងៃទី ១៣-០២-២០១២ របស់អភិបាលខណ្ឌចំការមនបានឡើយ គប្បីតុលាការសំរេចច្រានចោលចំណុចទាមទារនៅក្នុងបណ្តឹងតបចុះថ្ងៃទី ០៥-០៦-២០១២ ទាំងមូល ។

-ចុងចម្លើយមានកំហុសត្រូវទទួលបន្ទុកលើប្រាក់ប្រដាប់ក្តី និងពន្ធផ្សេងៗ ។

-យោងតាមមាត្រា ៦៩, មាត្រា ១២៣ និងមាត្រា ១៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-យោងតាមមាត្រា ៤០៧ និងមាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណី។

**សេចក្តីសម្រេចចុងក្រោយ**

១-ច្រានចោលចំណុចទាមទារនៅក្នុងបណ្តឹងតបចុះថ្ងៃទី ០៥-០៦-២០១២ របស់មេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយទាំងមូល ។

២-បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] ពៅ និងប្រពន្ធឈ្មោះ [redacted] មុំ ប្រគល់ផ្ទះលេខ ៦២$E_2$ ផ្លូវលេខ ២៤៥ ក្រុម២ ភូមិ១ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ និងលិខិតពាក់ព័ន្ធផ្ទះលេខ 62$E_2$ ទាំងអស់ ឲ្យទៅភាគីដើមចោទឈ្មោះ [redacted] ចាន់យ៉ារ៉េត និងប្រពន្ធឈ្មោះ [redacted] ស្រីមុំ ចាប់ពីថ្ងៃសាលក្រមស្ថាពរ។

៣-បង្គាប់ដើមចោទឈ្មោះ [redacted] ចាន់យ៉ារ៉េត និងប្រពន្ធឈ្មោះ [redacted] ស្រីមុំ សងប្រាក់ថ្លៃផ្ទះលេខ ៦២$E_2$ ផ្លូវលេខ ២៤៥ ក្រុម២ ភូមិ១ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ បង្គ្រប់ចំនួន៤៣.០០០$(បួនម៉ឺនបីពាន់ដុល្លារអាមេរិក)ឲ្យទៅ



Scanned with CamScanner

ភាគីចុងចម្លើយឈ្មោះ [redacted] ពៅ និងប្រពន្ធឈ្មោះ [redacted] មុំ ចាប់ពីថ្ងៃសាលក្រមស្ថាពរ។

៩-បង្គាប់ឲ្យចុងចម្លើយទទួលបន្ទុកលើប្រាក់ប្រដាប់ក្តី ។

-សាលក្រមនេះទាញហេតុផលផ្ទាល់មាត់នៅថ្ងៃទី ២៥-០៩-២០១២ និង ប្រកាសជាសាធារណៈនៅថ្ងៃទី ២២-១០-២០១២ ចំពោះមុខមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ និងមេធាវីតំណាងដោយអាណត្តិឲ្យចុងចំលើយ បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជី**
ហត្ថលេខា និងត្រា: [redacted]

**ចៅក្រមជំនុំជំរះ**
ហត្ថលេខា និងត្រា [redacted]

---

**បានឃើញ**
**ចៅក្រមជំនុំជំរះ**
[redacted]

«បានចំលងត្រឹមត្រូវតាមច្បាប់ដើម»
ភ្នំពេញ ថ្ងៃទី 25 ខែ តុលា ឆ្នាំ២០១២
**ក្រឡាបញ្ជី**
[redacted]

បានទទួល
ថ្ងៃទី 02-11-2012
មេធាវី [redacted]

បានទទួល
ថ្ងៃទី 25 ខែ តុលា ឆ្នាំ 2012

[redacted] បានយកទៅ

បានទទួល
25-10-2012
មេធាវី [redacted]

394